# សេចក្តីប្រកាសព័ត៌មាន

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូពង្រីកវិសាលភាពកម្មវិធីប៊ីបដល់១៤ខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា

[សម្រាប់ផ្សព្វផ្សាយបន្ទាន់]

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២



**កម្មវិធី៖** សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលសិក្សាថ្មីចំនួន៤ទីតាំង នៃកម្មវិធី សមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប)

### សមាសភាពគណៈអធិបតី៖

- **ឯកឧត្តមបណ្ឌិត ពេជ សោភ័ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **ឯកឧត្តម សេរី ជំនះ** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
- **ឯកឧត្តម គង់ សោភ័ណ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល
- **លោក សាដា អ៊ូម៉ា អាឡាំ** តំណាងអង្គការយូណេស្កូប្រចាំព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីបច្ចេកទេស និងបុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូឯកជន និងស្ថាប័នមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ  លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាប៊ីប។

**កាលបរិច្ឆេទ និងពេលវេលា៖** ថ្ងៃពុធ ទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ ដល់ ១១:០០នាទីព្រឹក
**ទីកន្លែង៖** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
(ផែនទី Google map៖ https://goo.gl/maps/yGgrPz98BZaBHKPD6)

---

ប្រទេសកម្ពុជាបានអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍កន្លងមកនេះ។ តែទោះជាយ៉ាងណា យុវជននៅមានភាពខ្វះខាតជំនាញ និងសមត្ថភាព ដើម្បីបំពេញតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងពេលអនាគត។ ការបោះបង់ការសិក្សានៅតែជាការប្រឈមដ៏សំខាន់មួយនាពេលបច្ចុប្បន្ន ជាពិសេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ ដោយកត្តាសេដ្ឋកិច្ចជាមូលហេតុចម្បង។ ដោយសារភាពក្រីក្រ វិសមភាពយេនឌ័រ ពិការភាព និងទីតាំងភូមិសាស្ត្រ ក្រុមយុវជនងាយរងគ្រោះ ច្រើនតែប្រឈមនឹងហានិភ័យនៃការបោះបង់ការសិក្សា។ ជាមួយគ្នានេះដែរ ដោយសារកង្វះខាតគុណវុឌ្ឍិ និងជំនាញដែលចាំបាច់ យុវជនជាច្រើនមិនអាចទទួលបានឱកាសការងារសមរម្យ។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ បានចាប់ផ្តើមអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប-BEEP) ដើម្បីដើម្បីដោះស្រាយបញ្ហានេះ និងផ្តល់ជូនយុវជនក្រៅសាលានូវ ការអប់រំជាមូលដ្ឋាន និងឱកាសអភិវឌ្ឍជំនាញ។ កម្មវិធីនេះគឺជាផ្នែកមួយនៃកម្មវិធីការងារសមរម្យសម្រាប់យុវជននៅកម្ពុជា (DEY) ដែលជាគំនិតផ្តួចផ្តើមរួមគ្នាដោយអង្គការសហប្រជាជាតិ ដើម្បីគាំទ្រយុវជនកម្ពុជាឱ្យទទួលបានឱកាសការងារសមរម្យ និងផលិតភាពខ្ពស់។

នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ នឹងរៀបចំព្រឹត្តិការណ៍ផ្លូវការមួយ ដើម្បីបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមណ្ឌលសិក្សាប៊ីបថ្មីចំនួន៤ នៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តស្វាយរៀង។ ការបើកមណ្ឌលសិក្សាថ្មីនេះបានបង្កើនចំនួនមណ្ឌលសិក្សា ប៊ីប ចំនួន ២៦ ទីតាំងក្នុង១៤ ខេត្តក្រុង ដើម្បីធានាឱ្យបានថា យុវជននៅក្រៅសាលា និងយុវជនដែលងាយរងគ្រោះកាន់តែច្រើនក្នុងប្រទេសកម្ពុជាទទួលបានឱកាសអប់រំជាមូលដ្ឋានដើម្បីបន្តការបណ្តុះបណ្តាលជំនាញបន្ថែមទៀត និងដើម្បីគាំទ្រពួកគេឱ្យទទួលបានការងារប្រកបដោយផលិតភាពខ្ពស់។ ពិធីនេះនឹងធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ពេជ សោភ័ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការនៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តកណ្តាល តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា ដៃគូវិស័យឯកជន អ្នកសម្របសម្រួល និងអ្នកសិក្សាកម្មវិធីប៊ីប។
ដោយសារភាពក្រីក្រជាកត្តាចម្បងដែលជំរុញឱ្យមានការបោះបង់ការសិក្សានៅក្នុងប្រទេសកម្ពុជា យុវជនដែលនៅក្រៅសាលាភាគច្រើនបម្រើការងារពេញម៉ោងដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ។ ទម្រង់នៃការសិក្សាតាមទូរសព្ទដែលមានភាពបត់បែនបានតាមរយៈកម្មវិធីប៊ីប ផ្តល់ឱកាសឱ្យសិស្សបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិរបស់ពួកគេតាមរយៈវគ្គសិក្សាតាមអ៊ីនធឺណិតដោយឥតគិតថ្លៃ និងមិនរំខានដល់ការងារពេញម៉ោងរបស់ពួកគេ។ អ្នកសិក្សាដែលបានបញ្ចប់កម្មវិធីនេះ នឹងទទួលបានវិញ្ញាបនបត្រសមមូលថ្នាក់ទី៩ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអាចឱ្យពួកគេចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសនៅគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនៃក្រសួងអប់រំ យុជន

និងកីឡា។ មណ្ឌលសិក្សាប៊ីប បានបំពាក់ដោយសេវាអ៊ីនធឺណិត កុំព្យូទ័របទ្ទះ និងកុំព្យូទ័រ ដើម្បីគាំទ្របន្ថែមដល់អ្នកសិក្សា ដែលមិនមានលទ្ធភាពប្រើប្រាស់ទូរសព្ទវៃឆ្លាត ឬកុំព្យូទ័រផ្ទាល់ខ្លួន ។ ដើម្បីបង្ករភាពងាយស្រួលដល់អ្នកសិក្សា អ្នកសម្របសម្រួលសរុបចំនួន ៥០ នាក់ ដែលមានពីរនាក់សម្រាប់មជ្ឈមណ្ឌលសិក្សានីមួយៗ ត្រូវបានជ្រើសរើស និងទទួលបានការបណ្តុះបណ្តាលដើម្បីណែនាំ និងជួយគាំទ្រដល់អ្នកសិក្សា។ ចាប់តាំងពីការបើកមណ្ឌលសិក្សាដំបូងក្នុងឆ្នាំ ២០១៩ អ្នកសិក្សាជាង ១៥០០ នាក់បានទទួលអត្ថប្រយោជន៍ពីកម្មវិធីប៊ីប។

ជាមួយគ្នានេះដែរ កម្មវិធីប៊ីបក៏បានទទួលជោគជ័យក្នុងការបង្កើតភាពជាដៃគូសាធារណៈ និងឯកជន ក្នុងការគាំទ្រការអនុវត្ត និងពង្រីកវិសាលភាព ដើម្បីជំរុញអាទិភាពវិស័យអប់រំជាតិរបស់កម្ពុជា។ ដោយមានការគាំទ្រពីក្រុមហ៊ុនទូរគមនាគមន៍ ក្នុងការផ្តល់ឧបករណ៍សិក្សានិងសេវាអ៊ីនធឺណិត យុវជនដែលនៅក្រៅសាលាកាន់តែច្រើន បានសិក្សាតាមកម្មវិធីប៊ីបគ្រប់ពេលវេលា គ្រប់ទីកន្លែង។ ការគាំទ្រពីដៃគូវិស័យឯកជនពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញការអប់រំឌីជីថលនៅកម្ពុជា ដើម្បីគាំទ្រឱ្យយុវជនកម្ពុជាមានជំនាញឌីជីថល ដែលជាជំនាញដ៏សំខាន់មួយសម្រាប់សតវត្សរ៍ទី ២១។

បច្ចុប្បន្ននេះ កម្មវិធីប៊ីប ស្ថិតក្នុងដំណាក់កាលពង្រីកវិសាលភាព ដើម្បីបង្កើនការបញ្ចប់ការអប់រំជាមូលដ្ឋាន និងអភិវឌ្ឍធនធានមនុស្ស ក្នុងការគាំទ្រដល់គោលដៅរបស់កម្ពុជា ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ការពង្រីកនេះរួមមានការដាក់ឱ្យដំណើរការកម្មវិធីប៊ីបទូទាំងប្រទេស ពង្រឹងសមត្ថភាពអ្នកសម្របសម្រួលក្នុងការផ្តល់ការប្រឹក្សាអំពីអាជីពនិងការងារដល់អ្នកសិក្សា និងការកែលម្អលទ្ធភាពទទួលបានការសិក្សាសម្រាប់យុវជនដែលមានពិការភាព។

**អំពីកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប-BEEP)**

ប៊ីបគឺជាផ្នែកមួយនៃកម្មវិធី ការងារសមរម្យសម្រាប់យុវជននៅកម្ពុជា (DEY) ដំណាក់កាលទី ២ ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (SDC) ជាគំនិតផ្តួចផ្តើមសហប្រតិបត្តិការដ៏លេចធ្លោរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីនេះត្រូវបានចាប់ផ្តើមដោយក្រសួងទាំងពីរ និងអង្គការយូណេស្កូ ដើម្បីដោះស្រាយបញ្ហាអត្រាបោះបង់ការសិក្សាខ្ពស់នៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា។ ក្រោយពេលបញ្ចប់កម្មវិធីដោយជោគជ័យ អ្នកសិក្សានឹងទទួលបានវិញ្ញាបនបត្រសមមូលថ្នាក់ទី៩ ដែលទទួលស្គាល់ដោយក្រសួងទាំងពីរ។

ចំពោះព័ត៌មានបន្ថែមសូមទាក់ទងតាមរយៈ៖


- លោក **ឈាន សុធារិទ្ធិ** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  អ៊ីមែល៖ sothearith.chhean@yahoo.com ទូរសព្ទ៖ ០១០ ៦០៨ ១៨០
- លោក **រស់ ភារៈ** លេខាធិការនៃអគ្គនាយកដ្ឋានយុវជន ក្រសួងអប់រំ យុវជន និងកីឡា
  អ៊ីមែល៖ ros.phearak@moeys.gov.kh ទូរសព្ទ៖ ០១២ ៦១៧ ៨០៧
- លោក **លៀវ គឹមឡាយ** មន្ត្រីកម្មវិធីអប់រំ អង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា
  អ៊ីមែល៖ k.leav@unesco.org ទូរសព្ទ៖ ០៦៩ ៨៩១ ២៣៤